ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៣ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ និងមន្ត្រីជាប់កិច្ចសន្យា

**យោង ៖** -សេចក្តីណែនាំលេខ ២១ អយក -សណន ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការអនុវត្តអនុក្រឹត្យលេខ ៥៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា

-អនុក្រឹត្យលេខ ៥៦ អនក្រ-បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ។

កន្លងមកក្រសួងអប់រំ យុវជន និងកីឡាបានពិនិត្យឃើញថា មានអង្គភាពមួយចំនួនមិនទាន់បានអនុវត្តពេញលេញតាមខ្លឹមសារអនុក្រឹត្យលេខ ៥៦ អនក្រ-បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ នៅឡើយ ដើម្បីបន្តពង្រឹងការងារគ្រប់គ្រង និងវិន័យការងារសម្រាប់បុគ្គលិកអប់រំ បម្រើការងារនៅតាមអង្គភាពចំណុះទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ក្រសួងស្នើសុំ **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាព** អនុវត្តដូចតទៅ ៖

១-ផ្សព្វផ្សាយអនុក្រឹត្យលេខ ៥៦ អនក្រ-បកចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ឲ្យបានទូលំទូលាយដល់គ្រប់បុគ្គលិកអប់រំក្រោមឱវាទ និងមន្ត្រីជាប់កិច្ចសន្យាក្នុងអង្គភាពរបស់ខ្លួន

២-ចាត់តាំងពិនិត្យឡើងវិញនូវតារាង ឬបញ្ជីសម្រង់វត្តមានប្រចាំថ្ងៃ ធ្វើយ៉ាងណាបង្កលក្ខណៈងាយស្រួលដល់បុគ្គលិកអប់រំ និងមន្ត្រីជាប់កិច្ចសន្យាក្នុងការចុះវត្តមាន មុន និងក្រោយពេលបំពេញការងារប្រចាំថ្ងៃឲ្យបានទាន់ពេលវេលា និងងាយស្រួលដល់ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ក្នុងការប្រមូលទិន្នន័យរៀបចំរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍ និងប្រចាំខែរបស់បុគ្គលិកអប់រំ និងមន្ត្រីជាប់កិច្ចសន្យា និងរក្សាទុកសម្រាប់ជាឯកសារក្នុងអង្គភាព

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ / ២១៧ ២៥៣ / ៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

៣-អនុវត្តវិន័យរដ្ឋបាលចំពោះបុគ្គលិកអប់រំទាំងឡាយណាដែលអវត្តមានដោយគ្មានច្បាប់ ដូចមានចែងក្នុងមាត្រា ១៧ មាត្រា ១៨ និងមន្ត្រីជាប់កិច្ចសន្យាអវត្តមានគ្មានច្បាប់ដូចមានចែងក្នុង មាត្រា ២៣ និងមាត្រា ២៤ នៃអនុក្រឹត្យលេខ ៥៦ អនក្រ-បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ រួចផ្ញើរបាយការណ៍មកក្រសួងអប់រំ យុវជន និងកីឡា ( នាយកដ្ឋានបុគ្គលិក )

៤-ស្នើសុំមកក្រសួងអប់រំ យុវជន និងកីឡាដើម្បីផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ ឬលុបឈ្មោះចេញពីតារាងដំឡើងឋានន្តរស័ក្តិឬថ្នាក់ និងលុបឈ្មោះចេញពីក្របខណ្ឌ ចំពោះបុគ្គលិកអប់រំ ទាំងឡាយណាដែលអវត្តមានគ្មានច្បាប់ ដូចមានចែងក្នុងមាត្រា ១៩ មាត្រា ២០ និងមាត្រា ២៥ ចំពោះ មន្ត្រីជាប់កិច្ចសន្យា ។

ក្រសួងនឹងចាត់តាំងអង្គភាពដែលមានសមត្ថកិច្ចចុះពិនិត្យមើល ការអនុវត្តអនុក្រឹត្យលេខ ៥៦ អនក្រ-បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និង មន្ត្រីជាប់កិច្ចសន្យា តាមអង្គភាពចំណុះទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ។ ក្នុងករណីគេឃើញថា ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ធ្វេសប្រហែសក្នុងការគ្រប់គ្រងវត្តមានរបស់បុគ្គលិកអប់រំ និងមន្ត្រីជាប់កិច្ច សន្យាក្រោមឱវាទមិនបានល្អប្រសើរនោះទេ ក្រសួងនឹងចាត់វិធានការតាមច្បាប់ដែលនៅជាធរមាន ។

ទទួលបានសេចក្តីណែនាំនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ប្រធានអង្គភាព ចំណុះទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាព ។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**ចម្លងជូន** ៖

- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួង អយក «ដើម្បីជូនជ្រាបជាព័ត៌មាន»
- គ្រប់អង្គភាពចំណុះទីស្តីការក្រសួង អយក « ដើម្បីអនុវត្ត »
- ឯកសារ កាលប្បវត្តិ-
- នាយកដ្ឋានបុគ្គលិក